VCP

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៦៣
ចុះថ្ងៃទី០៨-៦-២០១១
សាលដីកា
លេខ: ៧៥ ក្រVI.ប
ចុះថ្ងៃទី៣០-៩-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី១៥-៩-២០១៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៨៦៣ ចុះថ្ងៃទី០៨-៦-២០១១ រវាង:

- ជនជាប់ចោទឈ្មោះ: KATO [redacted] ភេទប្រុស អាយុ៤០ឆ្នាំ ជាតិជប៉ុន កើតនៅទីក្រុង[redacted] ទីលំនៅមុនពេលចាប់ខ្លួន [redacted] មុខរបរបុគ្គលិកភោជនីយដ្ឋាន ឪពុកឈ្មោះ: [redacted] ម្តាយឈ្មោះ: [redacted] ចាប់ខ្លួនថ្ងៃទី ០៧-៩-២០០៩ ឃុំខ្លួនថ្ងៃទី១០-៩-២០០៩ ។

- មានមេធាវីការពារសិទ្ធិឲ្យ លោក [redacted] ចន្ថា ។

ជាប់ចោទពីបទ: ទិញសេវាផ្លូវភេទពីអនីតិជន ប្រព្រឹត្តនៅផ្ទះលេខ ១៥៩ ផ្លូវលេខ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ។

១១១

- ជនរងគ្រោះឈ្មោះ [redacted] អានយឿន ហៅ ហ្វូវ ភេទស្រី អាយុ១៣ឆ្នាំ ជាតិវៀតណាម កើតនៅភូមិ [redacted] ទីលំនៅផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ។

- មានមេធាវីការពារសិទ្ធិឲ្យ លោកស្រី [redacted] សូនី និងលោក [redacted] ណារ៉ា ។

- តាមបណ្ដឹងឧទ្ធរណ៍លេខ ៧៧៦ ចុះថ្ងៃទី០៤-១១-២០១០ របស់មេធាវី [redacted] ជានិត និង [redacted] ម៉ាណែត ជាមេធាវីទទួលសិទ្ធិប្ដឹងឧទ្ធរណ៍ពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥កប.៥ ចុះថ្ងៃទី១៣-១០-២០១០ ត្រង់ចំណុចវិនិច្ឆ័យសេចក្ដីពាក់ព័ន្ធនឹងការផ្ដល់សំណងជម្ងឺចិត្ត ។

- តាមបណ្ដឹងឧទ្ធរណ៍លេខ ៧៨០ ចុះថ្ងៃទី០៥-១១-២០១០ របស់ជនជាប់ចោទឈ្មោះ KATO [redacted] ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប.៥ ចុះថ្ងៃទី ១៣-១០-២០១០ ត្រង់ចំណុច សេចក្ដីសំរេចសាលក្រមទាំងមូល ។

## ឯរឿងហេតុមានដូចតទៅ:

នៅថ្ងៃទី០៧-៨-២០០៩ជនជាតិជប៉ុនដែលជាជនជាប់ចោទឈ្មោះ KATO [redacted] បានប្រព្រឹត្តអំពើរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] អានយឿន ហៅ ហ្វូវ នៅក្នុងផ្ទះបនលេខ ១៥៩ ផ្លូវលេខ ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ហើយត្រូវបានសមត្ថកិច្ចចុះបង្ក្រាប និងចាប់ខ្លួនបាន នៅថ្ងៃទី០៧-៩-២០០៩ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប៥ ចុះថ្ងៃទី១៣-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

១- ផ្ដន្ទាទោស:

- ឈ្មោះ KATO [redacted] ភេទប្រុស អាយុ៤០ឆ្នាំ ជាតិជប៉ុន ដាក់ពន្ធនាគារកំណត់ចំនួន០៧ឆ្នាំ (ប្រាំពីរឆ្នាំ) និងហាមឃាត់មិនឲ្យស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្រោយពីអនុវត្តទោសចប់ ពីបទ: ទិញពេស្យាចារកុមារ ប្រព្រឹត្តនៅផ្ទះលេខ ១៥៩ ផ្លូវលេខ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្ដីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២- បង្គាប់ឲ្យឈ្មោះ KATO [redacted] សងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ៤០០.០០០៛ (សែសិបម៉ឺនរៀល) ទៅឲ្យជនរងគ្រោះនៅពេលសាលក្រមស្ថាពរ ។

៣- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១-៩-២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣-១០-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ KATO [redacted] មេធាវីការពារ

ជនជាប់ចោទ មេធាវីការពារជនរងគ្រោះ និងជនរងគ្រោះ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងច្បាប់កំណត់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧៧៦ ចុះថ្ងៃទី០៥-១១-២០១០ របស់មេធាវី [redacted] ជានិត និង [redacted] ម៉ាណែត ជាមេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប.៥ ចុះថ្ងៃទី១៣-១០-២០១០ ត្រង់ចំណុច វិនិច្ឆ័យសេចក្តីពាក់ព័ន្ធនឹងការផ្តល់សំណងជម្ងឺចិត្ត ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧៨០ ចុះថ្ងៃទី០៥-១១-២០១០ របស់ជនជាប់ចោទឈ្មោះ KATO [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប.៥ ចុះថ្ងៃទី១៣-១០-២០១០ មិនសុខចិត្តត្រង់ចំណុច សេចក្តីសំរេចសាលក្រមទាំងមូល ។

- បានឃើញ ពាក្យសុំដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១-៤-២០១៤ របស់ជនជាប់ចោទឈ្មោះ KATO [redacted]។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១១-៩-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## <u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ KATO [redacted] (វត្តមាន)
- មានមេធាវីការពារសិទ្ធិ លោក [redacted] ចន្ថា (វត្តមាន)
- អ្នកបកប្រែភាសា លោក សួស សំអាត (វត្តមាន)
- ជនរងគ្រោះឈ្មោះ [redacted] អានយឿន (អវត្តមាន)
- មានមេធាវីការពារសិទ្ធិ លោកស្រី [redacted] សូនី និងលោក [redacted] ណារ៉ា (វត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

- ជនជាប់ចោទឈ្មោះ KATO [redacted] បានឆ្លើយថា ខ្លួនសុំគោរពក្រុមប្រឹក្សា និងក្រឡាបញ្ជី និងអស់លោកទាំងអស់ និងសុំថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ខ្លួនសុំដកពាក្យបណ្តឹងឧទ្ធរណ៍ហើយ មកដល់តុលាការសាលាឧទ្ធរណ៍ ខ្លួនត្រូវបានតុលាការដាក់ទោស ០៧ឆ្នាំ ហើយខ្លួនមកនៅក្នុងពន្ធនាគារតាំងពីថ្ងៃទី១០-៩-២០០៩ មកដល់ពេលនេះខ្លួននៅក្នុងពន្ធនាគារអស់រយៈពេលជិត ៥ឆ្នាំហើយ គឺស្មើនឹង ៧០%នៃទោស សព្វថ្ងៃនេះម្តាយខ្លួនមានជម្ងឺមហារីកដោះ និងមានកូនតែខ្លួនម្នាក់គត់ ហើយគាត់រង់ចាំខ្លួនអស់រយៈពេលជិត ៥ឆ្នាំហើយ សូមលោកអនុញ្ញាតឲ្យខ្លួនបានវិលត្រឡប់ទៅផ្ទះ ដើម្បីបានមើលថៃម្តាយជាចុងក្រោយផង ។ នៅផ្ទះស្រីខូចវៀតណាម នាងនោះបានទទួលភ្ញៀវ ០៥នាក់ ក្នុងមួយថ្ងៃ និង ១៥០នាក់ក្នុងមួយខែរួចហើយ ហេតុអ្វីមកចាប់ខ្លួនតែម្នាក់ឯង ខ្លួនមិនយល់ ។ ខ្លួនជាប់ពន្ធនាគារអស់រយៈពេលជិត ៥ឆ្នាំហើយ មិនមានលទ្ធភាពក្នុងការសងសំណងទៅ

១១៣

ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ។ សំណូមពរ សុំកុំឲ្យខ្លួនសងសំណងទៀត ព្រោះខ្លួនជាប់ពន្ធនាគារយូរហើយ ។

**តំណាងមហាអយ្យការសន្និដ្ឋានថា:**

ជនជាប់ចោទបានសុំដកពាក្យបណ្ដឹងរបស់គាត់វិញ ហើយព្រមទទួលយកសេចក្ដីសម្រេចរបស់សាលាដំបូង រួចហើយចំពោះសំណង សូមក្រុមប្រឹក្សាមេត្តាពិនិត្យ និងសម្រេចតាមភាពជាក់ស្ដែង ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋាន:**

- លោកស្រី [redacted] សូនី និង លោក [redacted] ណារ៉ា ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា: ពាក់ព័ន្ធនឹងសំណងជម្ងឺចិត្តកូនក្ដីខ្លួនបានទាមទារសំណងចំនួន ៦.០០០$ (ប្រាំមួយពាន់ដុល្លាអាមេរិក) ប៉ុន្តែតុលាការសម្រេចឲ្យតែ ៨០ម៉ឺនរៀល ប៉ុណ្ណោះ បើផ្អែកនឹងបទល្មើស អំពើដែលប្រព្រឹត្តនោះ គឺធំធេង ចំណែកប្រាក់ដែលមានចំនួន ៨០ម៉ឺនរៀលនេះ គឺមានលក្ខណៈតិចតួចបំផុត ពេលនេះកូនក្ដីខ្លួននៅតែទាមទារសំណងចំនួន ៦.០០០$ (ប្រាំមួយពាន់ដុល្លាអាមេរិក) ដដែល និងសុំឲ្យក្រុមប្រឹក្សាមេត្តាពិនិត្យ និងសម្រេច លើសំណងតាមការទាមទាររបស់កូនក្ដីខ្លួនផង ។

- លោក [redacted] ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា: កូនក្ដីខ្លួនបានសុំដកពាក្យបណ្ដឹងឧទ្ធរណ៍ហើយ ពាក់ព័ន្ធនឹងសំណងទុកសិទ្ធិឲ្យក្រុមប្រឹក្សាសម្រេច តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ។

- ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ
- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍យល់ឃើញថា:**

១- បណ្ដឹងឧទ្ធរណ៍លេខ ៧៨០ ចុះថ្ងៃទី០៥-១១-២០១០ របស់ជនជាប់ចោទឈ្មោះ KATO [redacted] និងបណ្ដឹងឧទ្ធរណ៍លេខ ៧៧៦ ចុះថ្ងៃទី០៤-១១-២០១០ របស់មេធាវី [redacted] ជានិត និង [redacted] ម៉ាណែត ជាមេធាវីទទួលសិទ្ធិប្ដឹងឧទ្ធរណ៍ពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បណ្ដឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចជំនុំជម្រះបាន ។

១១៤

២- តាមអង្គហេតុ នៅថ្ងៃទី០៧-៨-២០០៩ជនជាតិជប៉ុនដែលជាជនជាប់ចោទឈ្មោះ KATO [redacted] បានប្រព្រឹត្តអំពើរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] អានយឿន ហៅ ហូវ នៅក្នុងផ្ទះបនលេខ ១៥៩ ផ្លូវលេខ ៦៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ហើយត្រូវបានសមត្ថកិច្ចចុះបង្ក្រាប និងចាប់ខ្លួនបាន នៅថ្ងៃទី០៧-៩-២០០៩ ។

៣- នៅចំពោះមុខសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ KATO [redacted] បានដាក់ពាក្យសុំដកបណ្តឹងឧទ្ធរណ៍តាមពាក្យស្នើសុំ ចុះថ្ងៃទី២២-៤-២០១៤ ដូចនេះសាលាឧទ្ធរណ៍គប្បីលើកមកពិចារណា ដើម្បីចំណាយរឿងចេញពីបញ្ជីក្តីរបស់សាលាឧទ្ធរណ៍ តែដើមបណ្តឹងរដ្ឋប្បវេណីក៏បានប្តឹងឧទ្ធរណ៍មកដែរ ដោយមិនសុខចិត្តនឹងការដែលសាលាដំបូងរាជធានីភ្នំពេញ បង្គាប់ឲ្យសងជម្ងឺចិត្តចំនួន ៤០ម៉ឺនរៀលនោះ ឃើញថា មិនធូនល្មមនឹងខាតបង់សេចក្តីថ្លៃថ្នូរ កិត្តិយស រួមទាំងផ្លូវចិត្ត និងសុខភាពទៀត ។ ដូចនេះសាលាឧទ្ធរណ៍គប្បីលើកមកពិចារណាតាមការស្នើសុំឲ្យបានសមស្របតាមច្បាប់ ។

៤- រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេតនឹងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ

៥- សាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប.៥ ចុះថ្ងៃទី១៣-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ លើកលែងតែសំណងជម្ងឺចិត្ត គប្បីមានការកែប្រែជាថ្មីតាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## ទនិច្ឆ័យសេចក្តៈ

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៧៦ ចុះថ្ងៃទី០៤-១១-២០១០ របស់មេធាវី [redacted] ជានិត និង [redacted] ម៉ាណែត ជាមេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គុង ទុកជាត្រឹមត្រូវតាមច្បាប់ ។

- ទទួលពាក្យសុំដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២-៤-២០១៤ របស់ជនជាប់ចោទឈ្មោះ KATO [redacted] ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៥ កប.៥ ចុះថ្ងៃទី១៣-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែសំណងជម្ងឺចិត្តត្រូវកែប្រែពី ៤០ម៉ឺនរៀល ទៅជា ៥លានរៀលវិញ ។ ចំណុចផ្សេងក្រៅពីនេះរក្សាទុកនៅដដែល ។

៣- បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ KATO [redacted] ។

១១៤

៨- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥-៩-២០១៤ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០-៩-២០១៤ ។

- បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី....ខែ.....ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

១១៦